**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**អគ្គនាយកដ្ឋានស្រាវជ្រាវ**
**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការនាំចូលក្រណាត់សម្រាប់ឧស្សាហកម្មកាត់ដេរបាន កើនឡើងដល់ ៣,៥ប៊ីលានដុល្លាររយៈពេល៩ខែដំបូងនៃឆ្នាំ២០២១
- អគ្គនាយកដ្ឋានពន្ធដារប្រមូលពន្ធបានជាង២,៥ប៊ីលានដុល្លារ កើនឡើង១៤% ក្នុង១១ខែដំបូងឆ្នាំ២០២១
- ABA ទិញមូលបត្របំណុលតម្លៃ ៣០លានដុល្លារ ពីក្រុមហ៊ុនសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោ
- ក្រសួងសេដ្ឋកិច្ចដាក់ឱ្យដំណើរការកម្មវិធីថ្នាក់ជាតិ ជួយអាជីវកម្មបង្កើតថ្មីៗ និងលើកកម្ពស់សហគ្រិនភាព
- គ្រាប់ស្វាយចន្ទីនាំចេញ ច្រើនលើសស្រូវ-អង្ករដល់ទៅជាង៦០០លានដុល្លារនៅ១១ខែក្នុងឆ្នាំ២០២១
- កម្ពុជានឹងបាត់បង់ភាពប្រកួតប្រជែង ប្រសិនការដឹកជញ្ជូននៅតែថ្លៃជាងប្រទេសដទៃ
- ការនាំចេញរបស់ប្រទេសកូរ៉េកើនឡើងខ្លាំងក្នុងខែវិច្ឆិកា ឆ្នាំ២០២១
- នៅក្នុងឆ្នាំ២០២២ ឱនភាពថវិការបស់ប្រទេសឥណ្ឌូនេស៊ីនឹងធ្លាក់ចុះទាបជាង ៤,៨៥% នៃផ.ស.ស
- ធនាគារពិភពលោករក្សាកំណើនសេដ្ឋកិច្ចរបស់ថៃត្រឹម ១% នៅក្នុងឆ្នាំ២០២១ ដោយរំពឹងថាអាចនឹងមានភាពល្អប្រសើរនៅក្នុងឆ្នាំ២០២២
- ធនាគារអភិវឌ្ឍអាស៊ី(ADB) បន្ទាបការព្យាករកំណើនសេដ្ឋកិច្ច នៃប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ឆ្នាំ២០២១ និងឆ្នាំ២០២២
- សេដ្ឋវិទូរំពឹងថា អតិផរណាក្នុងសហរដ្ឋអាមេរិក នឹងថមថយចុះឆាប់ៗនេះ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២១ លេខ ៖ ៩៨

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## ការនាំចូលក្រណាត់សម្រាប់ឧស្សាហកម្មកាត់ដេរបាន កើនឡើងដល់ ៣,៥ប៊ីលានដុល្លារក្នុង រយៈពេល ៩ខែ ដំបូងនៃឆ្នាំ២០២១



*ប្រភព៖Khmer times, 2021*

យោងតាមការធ្វើបច្ចុប្បន្នភាពសេដ្ឋកិច្ចចុងក្រោយរបស់ធនាគារពិភពលោកសម្រាប់ប្រទេសកម្ពុជាក្នុងរយៈពេលប្រាំបួនខែដំបូងនៃឆ្នាំនេះ កម្ពុជាបាននាំចូលក្រណាត់សម្រាប់ផលិតសម្លៀកបំពាក់ប្រមាណ ៣,៥ ប៊ីលានដុល្លារកើនឡើងជាង២៥% ដែលនេះអាចបញ្ជាក់បានថា វិស័យកាត់ដេរនៅកម្ពុជាមានដំណើរការល្អទាំងផ្នែកផលិតកម្ម ការនាំចេញ និងកំណើននៃការបញ្ជាទិញ។ លោក កាំង ម៉ូនីកា អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរកម្ពុជា បានបញ្ជាក់ថា ការកើនឡើងនៃការនាំចូលវត្ថុធាតុដើមសម្រាប់ផលិតសម្លៀកបំពាក់នៅឆ្នាំនេះ គឺស្របទៅនឹងកំណើននៃការនាំចេញសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរ។

សម្រាប់កំណើនក្នុងវិស័យនីមួយៗមានភាពខុសគ្នាបន្តិចបន្តួចដោយវិស័យសម្លៀកបំពាក់ត្រូវបានមើលឃើញថាមានកំណើនទាបបំផុតប្រហែល ៥% ក្នុងរយៈពេល ៩ខែដំបូងនៃឆ្នាំនេះ ប៉ុន្តែវិស័យស្បែកជើងកើនឡើងប្រហែល ១៥% ហើយសម្រាប់ផលិតផលធ្វើដំណើរក៏មានកំណើនខ្លាំងបន្ថែមទៀតជាង ៣00% បើធៀបនឹងឆ្នាំមុន។ វិស័យសម្លៀកបំពាក់គឺជាផលិតផលដែលមានកំណើនទាប ហើយមានការប្រកួតប្រជែងខ្លាំងជាមួយប្រទេសផ្សេងទៀត ជាពិសេសបង់ក្លាដែស និងវៀតណាម។

ក្នុងឆ្នាំ២០២១ ស្ថានភាពនៃវិស័យកាត់ដេរនៅកម្ពុជាមានភាពប្រសើរឡើងដោយសារ ផលិតកម្មមានស្ថិរភាព ដែលនាំឱ្យមានការនាំចេញកើនឡើង ខណៈដែលការបញ្ជាទិញក៏កើនឡើងផងដែរ បើប្រៀបធៀបទៅនឹងឆ្នាំ ២០២០។

ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិកបានកើនឡើង ៣១,៩% ស្មើនឹង ៣,៤ ប៊ីលានដុល្លារក្នុងខែកញ្ញា ឆ្នាំ២០២១ បើទោះបីជាប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទូទៅ (GSP) មិនទាន់មានសុពលភាពក៏ដោយ។ ទន្ទឹមនឹងនេះ រោងចក្រដែលបានផ្អាកការផលិតកាលពីដើមឆ្នាំបានដំណើរការផលិតឡើងវិញជាធម្មតា។

ទិន្នន័យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានបង្ហាញថា ក្នុងរយៈពេល៩ខែដំបូងឆ្នាំនេះកានាំចេញសម្រៀកបំពាក់មានចំនួន៨,១៤ប៊ីលានដុល្លារកើនឡើង ១១,៤% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០៕*ដោយ សេន ចន្ទ*

*ប្រភព៖ Khmer Times, ចេញផ្សាយថ្ងៃទី១៤ខែធ្នូ ឆ្នាំ២០២១*

## អគ្គនាយកដ្ឋានពន្ធដារប្រមូលពន្ធបានជាង២,៥ប៊ីលានដុល្លារ កើនឡើង១៤% ក្នុង១១ខែដំបូងឆ្នាំ២០២១



*ប្រភព៖ ខ្មែរថាម , ២០២១*

ក្នុងរយៈពេល ១១ ខែដើមឆ្នាំនេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធចូលថវិកាជាតិសរុបចំនួន ២,៥៦ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១១៤,១៣% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានលើកឡើងថា ក្នុងខែវិច្ឆិកា ចំណូលពន្ធគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៩៩០,២៩ប៊ីលានរៀល (ប្រមាណ ២៤៤,៥២ លានដុល្លារ) ស្មើនឹង ដល់ ១០.៩០% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។

បើប្រៀបធៀបនឹងចំណូលពន្ធក្នុងខែវិច្ឆិកា ឆ្នាំ ២០២០ នេះបានកើនឡើងចំនួន ៤៩,៣១ ប៊ីលានរៀល (ប្រមាណ ១២,១៧ លានដុល្លារ) ស្មើនឹង ៥,២៤% ។

ទន្ទឹមនឹងនេះ កត្តាដែលបង្កើនលទ្ធផលប្រមូលចំណូលពន្ធក្នុងខែវិច្ឆិកា និងសម្រេចផែនការឆ្នាំ២០២១ មានដូចជា៖

១-ការគ្រប់គ្រងពេញលេញ និងមានប្រសិទ្ធភាពនៃស្ថានភាពជំងឺកូវីដ-១៩ តាមរយៈការចាត់វិធានការជាយុទ្ធសាស្ត្រក្នុងការចាក់វ៉ាក់សាំងដល់ប្រជាជនកម្ពុជាបានទាន់ពេលវេលា។

២-បន្តពង្រឹងអភិបាលកិច្ចល្អ និងរដ្ឋបាលល្អ ព្រមទាំងប្រកាន់ខ្ជាប់នូវស្មារតីសកម្ម ជាពិសេសការអភិវឌ្ឍន៍ និងដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យា មុនការផ្ទុះឡើងនៃជំងឺកូវីដ-១៩។

៣-ផ្តល់នូវមូលដ្ឋានទិន្នន័យគ្រប់គ្រាន់សម្រាប់ការអនុវត្តការគ្រប់គ្រងការចុះបញ្ជីពន្ធដារសហគ្រាស

៤-ពង្រឹងការចុះបញ្ជីពន្ធដារតាមរយៈប្រព័ន្ធបច្ចេកវិទ្យា និង

៥-បន្តពង្រឹងការធ្វើបច្ចុប្បន្នភាពសហគ្រាសស្របតាមខ្លឹមសារនៃប្រកាសលេខ ៧០១ អនក្រក ចុះថ្ងៃទី ថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០២០ ស្តីពីការចុះបញ្ជីសារពើពន្ធ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ ដែលផ្តល់ការការពារទាន់ពេលវេលានៃគ្រប់ទម្រង់នៃការគេចពន្ធ។

*ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាម ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១*

## ABA ទិញមូលបត្របំណុលតម្លៃ ៣០លានដុល្លារ ពីក្រុមហ៊ុនសាងសង់អាកាសយានដ្ឋានអន្តរជាតិ តេជោ




*ដោយ Freshnews*

ធនាគារវឌ្ឍនៈអាស៊ីចំកាត់(ធនាគារABA) នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២១នេះ បានសម្រេចវិនិយោគ៣០លានដុល្លារ លើមូលបត្របំណុលរបស់ក្រុមហ៊ុនសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោ ចូលរួមគាំទ្រ

គម្រោងសាងសង់ព្រលានយន្តហោះថ្មីនេះនៅខេត្តកណ្តាល។ បច្ចុប្បន្ន គម្រោងសាងសង់នេះ សម្រេចបាន២៨% ត្រូវនឹងទឹកប្រាក់សរុប៣៧៥លានដុល្លារ (ដោយមិនរាប់បញ្ចូលថ្លៃដីដែលវិនិយោគរួចដោយ CAIC)។ CAIC គឺជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា(RGC)ដែលតំណាងដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រុមហ៊ុនOCIC។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិឱ្យ ក្រុមហ៊ុន CAIC ក្នុងការកាន់កាប់ រចនាប្លង់ សាងសង់ ធ្វើហិរញ្ញប្បទាន និងគ្រប់គ្រងប្រតិបត្តិការគម្រោង អាកាសយានដ្ឋានអន្តរជាតិតេជោ។ ក្រុមហ៊ុន OCIC គឺជាក្រុមហ៊ុនវិនិយោគក្នុងស្រុកមួយធំជាងគេ ក្នុងប្រទេសកម្ពុជា ដែលជំនាញនៅក្នុងការអភិវឌ្ឍន៍លើវិស័យហេដ្ឋារចនាសម្ព័ន្ធ អចលនទ្រព្យ សំណង់ ការគ្រប់គ្រងអចលនទ្រព្យ ការអប់រំ វេជ្ជសាស្ត្រ ផ្សារទំនើប សណ្ឋាគារ រោងម៉ាស៊ីនកិនស្រូវ និងសង្វាក់ផលិតកម្មជាដើម ជាមួយនឹងគម្រោងសំខាន់ៗជាច្រើនដូចជា អាកាសយានដ្ឋានអន្តរជាតិតេជោ ទីក្រុងកោះពេជ្រ កោះនរា ទីក្រុងរណបជ្រោយចង្វារ និង ទីក្រុងទំនើប Olympia ជាដើម។

ប្រមុខរាជរដ្ឋាភិបាលបានអំពាវនាវដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនានា ទាំងក្នុង និងក្រៅប្រទេស ឱ្យជួយទិញសញ្ញាបណ្ណ (មូលបត្របំណុល-Bond) របស់ក្រុមហ៊ុនខេមបូឌា អ៊ែរផត អ៊ិនវេសមិន (CAIC) ដែលសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោ។ ការចូលរួមទិញសញ្ញាបណ្ណនេះ គឺជាការចូលដល់ការអភិវឌ្ឍន៍ព្រលានយន្តហោះថ្មី ដែលកាត់បន្ថយនូវការប្រើប្រាស់ទុនពីក្រៅប្រទេស ហើយគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ ក៏ទទួលបានផលចំណេញពីអត្រាការប្រាក់ដោយទទួលបានការធានាផ្នែកហានិភ័យស្មើសូន្យពីរាជរដ្ឋាភិបាលផងដែរ៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ Freshnews ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។*

## រដ្ឋមន្ត្រីទេសចរណ៍ជំរុញវិស័យឯកជនត្រៀមទទួលភ្ញៀវនៅពេលឆ្លងឆ្នាំ



នៅចុងសប្តាហ៍ទី២នៃខែធ្នូ ឆ្នាំ២០២១នេះ កំណើនភ្ញៀវទេសចរផ្ទៃក្នុង មានការកើនឡើងលើសសប្តាហ៍មុនៗ ដោយភ្ញៀវទេសចរសរុបមានចំនួន ២២២ ៥២៧ នាក់ ក្នុងនោះភ្ញៀវជាតិ ២១៦ ៧០៩ នាក់ និងភ្ញៀវបរទេសផ្ទៃក្នុង ៥ ៨១៨ នាក់។ គោលដៅទេសចរណ៍សំខាន់ៗរួមមាន ខេត្តព្រះសីហនុ, រាជធានីភ្នំពេញ, ខេត្តកំពត, ខេត្តកំពង់ស្ពឺ, ខេត្តពោធិ៍សាត់, ខេត្តសៀមរាប, ខេត្តបាត់ដំបង, ខេត្តកែប និងខេត្តមណ្ឌលគិរី។តួលេខខាងលើមានការកើនឡើងប្រមាណ ២២,៩៣% ធៀបនឹងចុងសប្តាហ៍កន្លងមក។ ខេត្តព្រះសីហនុបានក្លាយជាគោលដៅទេសចរណ៍លំដាប់កំពូល ដែលទទួលបានភ្ញៀវទេសចរច្រើនជាងគេប្រចាំសប្តាហ៍ក្នុងរយៈពេល៣សប្តាហ៍ចុងក្រោយនេះ។

មន្ទីរទេសចរណ៍ និងរដ្ឋបាលរាជធានី-ខេត្ត បាននិងកំពុងខិតខំជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និង SOP ឱ្យបានគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍ ស្របពេលដែលក្រសួងទេសចរណ៍ក៏បានកំពុងតាមដានការគ្រប់គ្រងគោលដៅទេសចរណ៍ធំៗទាំងបី គឺខេត្តព្រះសីហនុ ខេត្តសៀមរាប និងរាជធានីភ្នំពេញ។ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានជំរុញដល់វិស័យឯកជន និងប្រតិបត្តិករទេសចរណ៍ត្រូវបន្តរៀបចំអាជីវកម្មខ្លួន

ឱ្យមានគុណភាពល្អ សម្រាប់ទទួលភ្ញៀវទេសចរនាឱកាសថ្ងៃឈប់សម្រាកឆ្លងឆ្នាំ២០២១ ឆ្លងចូល ២០២២ខាងមុខនេះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។*

## ក្រសួងសេដ្ឋកិច្ចដាក់ឱ្យដំណើរការកម្មវិធីថ្នាក់ជាតិ ជួយអាជីវកម្មបង្កើតថ្មីៗ និងលើកកម្ពស់សហគ្រិនភាព




*ដោយ ខេមបូណូមីស*

ជំងឺកូវីដ-១៩ មិនអាចបន្ទច់បង្អាក់សកម្មភាពប្រកបអាជីវកម្ម និងការធ្វើពាណិជ្ជកម្មផ្សេងរបស់ប្រជាពលរដ្ឋ ក៏ដូចជាមិនអាចរារាំងដល់សកម្មភាពណាមួយរបស់រាជរដ្ឋាភិបាលដែរ ហើយបានធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថនៃការរស់នៅ និងធុរៈកិច្ច។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យដំណើរការកម្មវិធីថ្នាក់ជាតិស្តីពី«ធុរកិច្ចថ្មីកម្ពុជា» ឬហៅថា Cambodia Startup ក្នុងគោលបំណងជួយលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី និងសហគ្រិនភាពនៅកម្ពុជា តាមរយៈការផ្តល់យន្តការ សម្របសម្រួលរវាងភាគីពាក់ព័ន្ធក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ឱ្យមានបរិស្ថានធ្វើធុរកិច្ចថ្មីមានភាពរស់រវើក និងមានលក្ខខណ្ឌអំណោយផលសម្រាប់ធុរកិច្ចថ្មីឱ្យជោគជ័យ ដើម្បីរួមចំណែកស្តារសេដ្ឋកិច្ច ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ និងរួមចំណែកកសាងសេដ្ឋកិច្ចឌីជីថលកម្ពុជា។ ការបង្កើត«ធុរកិច្ចថ្មី» ឬ Startup គឺជានិន្នាការសកលដែលបង្កើតឡើងដើម្បីឆ្លើយតបនឹងការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យា ដែលគេអាចបង្កើតជាសេវាកម្ម ឬផលិតផលបម្រើដល់ការរស់នៅរបស់មនុស្សជាតិឱ្យកាន់តែប្រសើរឡើង។

វិស័យStartup មានការរីកដុះដាលខ្លាំងគួរឱ្យកត់សម្គាល់នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ស្របពេលកម្ពុជាប្រកាសបើកសកម្មភាពសង្គម និងសេដ្ឋកិច្ចលើគ្រប់វិស័យឡើងវិញ *រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*បានជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធត្រូវចូលរួមក្នុងការបង្កើតអន្តរសកម្មរវាងតួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី, គ្រប់តួអង្គពាក់ព័ន្ធត្រូវចូលរួមយ៉ាងសកម្មក្នុងកម្មវិធីសហគមន៍ធុរកិច្ចថ្មីកម្ពុជា និងសិស្ស និស្សិត ធុរជន និងនវានុវត្តជនត្រូវពង្រឹងសមត្ថភាពទាំងជំនាញរឹង និងទន់តាមរយៈការរៀនសូត្រនៅតាមគ្រឹះស្ថានសិក្សា ការស្រាវជ្រាវ កម្មសិក្សា និងការចូលរួមគាំទ្រកម្មវិធីធុរកិច្ចថ្មីៗនានា ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើនធុរកិច្ចថ្មីប្រកបដោយនវានុវត្ត និងមានឱកាសទទួលបានជោគជ័យខ្ពស់។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញនូវគោលការណ៍មួយចំនួនផងដែរ ដើម្បីជួយឱ្យការអនុវត្តកម្មវិធីថ្នាក់ជាតិនេះប្រកបដោយប្រសិទ្ធិភាព និងទទួលបានជោគជ័យ។

ក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ក៏ត្រូវផ្តល់ការគាំទ្រដល់ការបង្កើតធុរកិច្ចថ្មី និងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីតាមវិស័យរៀងៗខ្លួន តាមរយៈការបញ្ជ្រាបការគាំទ្រទៅក្នុងផែនការប្រចាំឆ្នាំ និងការផ្តល់គោលនយោបាយលើកទឹកចិត្តនានា និងគ្រប់តួអង្គពាក់ព័ន្ធត្រូវចូលរួមចែករំលែកទិន្នន័យដែលមានគុណភាពនៅក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីជាដើម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១។*

## គ្រាប់ស្វាយចន្ទីនាំចេញ ច្រើនលើសស្រូវ-អង្ករដល់ទៅជាង៦០០លានដុល្លារនៅ១១ខែក្នុងឆ្នាំ២០២១



*ដោយ ខេមបូណ្ណមីស*

ការនាំចេញកសិផលកម្ពុជានៅជិតពេញមួយឆ្នាំ២០២១នេះ សម្រេចបានកំណើនខ្ពស់គួរឱ្យកត់សម្គាល់។ ក្នុងនោះដែរ ដំណាំគ្រាប់ស្វាយចន្ទីមានសក្តានុពលខ្ពស់ក្នុងការនាំចេញនៅ១១ខែដំបូងឆ្នាំ២០២១នេះ បើធៀបជាទឹកប្រាក់នៃការនាំចេញស្រូវអង្ករ ឃើញថាទឹកប្រាក់គ្រាប់ស្វាយចន្ទីមានលើសដល់ទៅជាង៦០០លានដុល្លារអាមេរិក។

នៅក្នុងរយៈពេល ១១ខែដំបូង ឆ្នាំ២០២១ ការនាំចេញស្វាយចន្ទីទៅក្រៅប្រទេស បានកើនឡើងដល់ទៅជាង៣០០%ឯណោះ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ នេះគឺដោយសារ មានតម្រូវការខ្លាំងពី បណ្តាប្រទេសផ្សេងៗដូចជា វៀតណាម និងចិន ហើយថ្មីៗនេះទៀតសោត ប្រទេសឥណ្ឌាក៏កំពុងតែមានតម្រូវការខ្លាំងណាស់ដែរ។

អ្នកនាំពាក្យសមាគមន៍ស្វាយចន្ទីកម្ពុជា បានរំពឹងទុកថា ស្វាយចន្ទីនឹងក្លាយជាដំណាំកសិកម្ម នាំចេញលេខ១ នៅក្នុងប្រទេសកម្ពុជានៅពេលខាងមុខនេះ ហើយក៏អាចនឹងនឹងក្លាយជាប្រទេសលំដាប់ទី១ក្នុងការនាំចេញស្វាយចន្ទីបានច្រើនជាងទៅកាន់ទីផ្សារពិភពលោកផងដែរ ដោយសារតែនៅរយៈ៥ ទៅ៦ឆ្នាំចុងក្រោយនេះ អត្រានៃការដាំដុះស្វាយចន្ទីនៅតាមបណ្តាប្រទេសផ្សេងៗមានការថយចុះ ខណៈបច្ចុប្បន្ន នៅកម្ពុជាកំពុងតែមានកំណើននៃការដាំដុះស្វាយចន្ទីកាន់តែច្រើនឡើង ដើម្បីជាការបំពេញតម្រូវការទីផ្សារក្រៅប្រទេសដែលកំពុងកើនឡើង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។*

## តើទីផ្សារខុនដូ អាចស្ទុះងើបឡើងវិញនៅពេលណា?



*(រូបភាព៖ ហេង ការម្យ)*

ទីផ្សារខុនដូនៅកម្ពុជា បានកម្រើកឡើងវិញជាបណ្តើរៗក្រោយពីរាជរដ្ឋាភិបាលកម្ពុជាប្រកាសបើកសកម្មភាពសេដ្ឋកិច្ចលើគ្រប់វិស័យឡើងវិញ។ ទាំងវិនិយោគិនក្នុងនិងក្រៅស្រុកចាប់ផ្តើមមានក្តីសង្ឃឹម ឡើងវិញហើយ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនភ្នាក់ងារអចលនទ្រព្យលើវិស័យនេះ ក៏ចាប់ផ្តើមមានប្រតិបត្តិការយ៉ាងផុសផុលឡើងវិញផងដែរ។

ប្រមាណពីរឆ្នាំកន្លងមកនេះ ទីផ្សារខុនដូនៅកម្ពុជា នៅតែមានចរន្តទិញលក់ ដែលផ្តោតលើអតិថិជនក្នុងស្រុក។ ពេលនេះវិនិយោគិនបរទេសសំឡឹងមើលឱកាសវិនិយោគលើវិស័យខុនដូនៅកម្ពុជាកាន់តែច្រើនក្រោយមានការបើកជើងហោះហើរកាន់តែទូលំទូលាយ។

ប្រធានសមាគមទីភ្នាក់ងារ និងវាយតម្លៃអចលនវត្ថុកម្ពុជាសង្កេតឃើញថា បច្ចុប្បន្នអតិថិជនក្នុងស្រុកបានចាប់ផ្តើមដើររកទិញខុនដូតាមគម្រោងនានា។ ប៉ុន្តែ សម្រាប់អតិថិជន និងអ្នកវិនិយោគបរទេសមិនទាន់មានសញ្ញាវិជ្ជមានជាដុំកំភួននៅឡើយទេនៅកម្ពុជា ទោះបីបាន

បើកប្រទេស និងលើកលែកការធ្វើចត្តាឡីស័កក៏ដោយ។ ទោះបីយ៉ាងនេះក្តី វិស័យខុនដូនេះនៅកម្ពុជានឹងមានភាពកំណើនខ្ពស់ក្រោយពិធីបុណ្យចូលឆ្នាំចិននៅឆ្នាំ ២០២២ ខាងមុខ។

អគ្គនាយកក្រុមហ៊ុនអចលនទ្រព្យ CPL បានលើកឡើងដែរថា ទីផ្សារខុនដូនៅកម្ពុជាបច្ចុប្បន្នភាគច្រើនពឹងផ្អែកលើជនបរទេស ខណៈទំនោរជនជាតិខ្មែរចូលចិត្តរស់នៅតាមផ្ទះដែលមានទីធ្លារធំទូលាយ និងនៅផ្ទាល់ដី ដោយសារកម្ពុជានៅសល់ដីទំនេរច្រើន។ ប៉ុន្តែ អ្នកជំនាញមានបទពិសោធន៍ជាង២០ឆ្នាំក្នុងវិស័យអចលនទ្រព្យរូបនេះជឿជាក់ថា ទៅថ្ងៃអនាគតទីផ្សារខុនដូ អាចជាវិស័យដ៏មានសក្តានុពលនៅកម្ពុជា និងគ្រប់ដណ្តប់ភាគច្រើនដោយអ្នកប្រើប្រាស់ក្នុងស្រុក៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។*

## កម្ពុជានឹងបាត់បង់ភាពប្រកួតប្រជែង ប្រសិនការដឹកជញ្ជូននៅតែថ្លៃជាងប្រទេសដទៃ




*ដោយ ខេមបូណូមីស(កំពង់ផែក្រុងព្រះសីហនុ)*

វិស័យដឹកជញ្ជូនជាសរសៃឈាមមួយរួមចំណែកជួយជំរុញកំណើនសេដ្ឋកិច្ច(ការនាំចេញ)។ កម្ពុជាអាចនឹងបាត់បង់ភាពប្រកួតប្រជែងក្នុងការជំរុញកំណើននាំចេញ និងទាក់ទាញវិនិយោគិនបរទេស ប្រសិនបើថ្លៃដឹកជញ្ជូនមានតម្លៃខ្ពស់ជាងប្រទេសដទៃ។ កន្លងមកការនាំចេញទំនិញតាមផ្លូវទឹក ត្រូវលើកផ្ទេរនៅកំពង់ផែតាមប្រទេសមួយចំនួន មុនដឹកបន្តទៅប្រទេសគោលដៅ។ ប្រធានសមាគមភស្តុភារកម្មកម្ពុជាទទួលស្គាល់ថា តម្លៃដឹកជញ្ជូនរបស់កម្ពុជាទៅក្រៅប្រទេស ពិតជាថ្លៃជាងប្រទេសជិតខាងប្រាកដមែន ដោយសារកម្ពុជាខ្វះហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យដឹកជញ្ជូន និងការដឹកដោយប្រើប្រាស់រថយន្តចាស់ៗ និងការគ្រប់គ្រងមិនបានល្អក្នុងការដឹកជញ្ជូនក្នុងស្រុក ក៏ជាកត្តារួមផ្សំផងដែរ។ មួយវិញទៀតកម្ពុជាពុំមានកំពង់ទឹកជ្រៅ ដែលអាចឱ្យកប៉ាល់ធំៗចូលចតបានដូចប្រទេសជិតខាងមួយចំនួន។ ទំនិញដែលនាំចេញពីកម្ពុជាទៅកាន់គោលដៅទីផ្សារឆ្ងាយៗ ត្រូវលើកដាក់ផ្ទេរនៅតាមប្រទេសមួយចំនួនសិនមុនដល់គោលដៅ ធ្វើឱ្យតម្លៃដឹកជញ្ជូនមានការកើនឡើងមួយកម្រិតទៀត។ ចំពោះការដឹកជញ្ជូនទំនិញក្នុងស្រុកមានតម្លៃប្រហាក់ប្រហែលនឹង ប្រជិតខាងដែរ។ មួយរយៈពេលចុងក្រោយនេះ ការដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសហាក់មានភាពល្អប្រសើរឡើងវិញបន្តិចហើយបន្ទាប់ពីការបើកប្រទេសឡើងវិញ និងលើកលែងការធ្វើចត្តាឡីស័កចំពោះអ្នកដំណើរចូលមកកម្ពុជា ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ រួច។ ប៉ុន្តែការដឹកជញ្ជូនតាមផ្លូវអាកាសមិនទាន់មានការរីកចម្រើនខ្លាំងនៅឡើយទេ។

អ្នកជំនាញក្នុងវិស័យនេះសង្ឃឹមថា ក្រោយរាជរដ្ឋាភិបាលកម្ពុជាលើកកម្ពស់គុណភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុពីកំពង់ផែទឹករាក់មកកំពង់ទឹកជ្រៅរួចរាល់ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធនានាបម្រើឱ្យវិស័យនេះ ព្រមជាមួយមានការបើកជើងហោះហើរទូលំទូលាយឡើងវិញផងនោះ វានឹងជួយស្តារ និងជំរុញកំណើននៃការដឹកជញ្ជូន និងនាំចេញទំនិញឱ្យកាន់តែល្អប្រសើរថែមទៀត៕

*ដោយ ម៉ែន ខែមរៈ*

# តារាងប្រចាំសប្តាហ៍

## តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងរយៈពេល១០ខែ ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថា នៅក្នុងរយៈពេល១០ខែ ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានទំហំទឹកប្រាក់សរុប ៦ ៦៦២ លានដុល្លារ មានកំណើនប្រមាណជា ៩,៦% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។

ជាក់ស្តែង ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជា មានទំហំទឹកប្រាក់ ៥ ៩១៥,៩៥លានដុល្លារ នៅក្នុងរយៈពេល ១០ខែ ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ១៦,៨% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។

ក៏ប៉ុន្តែ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៧៤៦, ០៥លានដុល្លារ នៅក្នុងរយៈពេល១០ខែ ឆ្នាំ២០២១ ដែលបានធ្លាក់ចុះប្រមាណជា ២៦,៣% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០៕

*ដោយ មិត្ត ចន្ទី*

***ឯកតា៖ គិតជាលានដុល្លារអាមេរិក***

| **បរិយាយ** | ១០ខែ ឆ្នាំ២០២០ | ១០ខែ ឆ្នាំ២០២១ | ការប្រែប្រួល |
|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | 6,077.73 | 6,662.00 | 9.6% |
| កម្ពុជានាំចេញទៅថៃ | 1,011.91 | 746.05 | -26.3% |
| ថៃនាំចូលមកកម្ពុជា | 5,065.82 | 5,915.95 | 16.8% |

ប្រភព៖*ធនាគារជាតិប្រទេសថៃ*

## តារាងទី២ ៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែកញ្ញា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែកញ្ញា ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ៤៤៣,០៦ប៊ីលានរៀល មានកំណើនប្រមាណជា ២១,៧% បើធៀបនឹងខែសីហា នៃឆ្នាំ ២០២១។

ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ១០៤,៧០ប៊ីលានរៀល នៅក្នុងខែកញ្ញា ឆ្នាំ២០២១ មានកំណើនប្រមាណជា ១០,៧% បើធៀបនឹងខែសីហា ឆ្នាំ២០២១។

ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ៣៣០,៣៦ប៊ីលានរៀល នៅក្នុងខែកញ្ញា ឆ្នាំ២០២១ មានកំណើនប្រមាណជា ២៨,២% បើធៀបនឹងខែសីហា ឆ្នាំ២០២១។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មិនមានទេនៅក្នុងខែកញ្ញាឆ្នាំ២០២១នេះ៕

*ដោយ មិត្ត ចន្ទី*

| ការចំណាយឆ្នាំ២០២១(គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា |
|---|---|---|---|---|---|---|---|---|---|
| អត្ថប្រយោជន៍សង្គម | **103.40** | **114.72** | **240.59** | **115.28** | **376.94** | **365.53** | **479.33** | **364.04** | **443.06** |
| កំណើន/ថយ(%) | | 10.9% | 109.7% | -52.1% | 227.0% | -3.0% | 31.1% | -24.1% | 21.7% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 | 92.81 | 99.99 | 99.76 | 94.59 | 104.70 |
| កំណើន/ថយ(%) | | 11.5% | 57.0% | -75.4% | 137.6% | 7.7% | -0.2% | -5.2% | 10.7% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 | 266.78 | 255.92 | 370.71 | 257.70 | 330.36 |
| កំណើន/ថយ(%) | | -7.2% | 751.1% | -12.8% | 306.4% | -4.1% | 44.9% | -30.5% | 28.2% |
| អំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ | 3.23 | 4.83 | 6.64 | 10.57 | 11.73 | 9.62 | 8.86 | 8.94 | 8.00 |
| កំណើន/ថយ(%) | | 49.5% | 37.5% | 59.2% | 11.0% | -18.0% | -7.9% | 0.9% | -10.5% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - | 5.62 | - | | 2.81 | - |

ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ខែកញ្ញា ឆ្នាំ២០២១

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ការនាំចេញរបស់ប្រទេសកូរ៉េកើនឡើងខ្លាំងក្នុងខែវិច្ឆិកា ឆ្នាំ២០២១

ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងថាមពលបានបង្ហាញថា ការនាំចេញរបស់ប្រទេសកូរ៉េនៅក្នុងខែវិច្ឆិកា បានកើនឡើង ៣២,១%ដែលមានតម្លៃស្មើនឹង ៦០,៤ ប៊ីលានដុល្លារ។ ក្នុងនោះការនាំចូលបានកើនឡើង

៤៣,៦%ឬស្មើនឹង៥៧,៤ ប៊ីលានដុល្លារ បានធ្វើឱ្យមានអតិរេកពាណិជ្ជកម្មចំនួន ៣,១ប៊ីលានដុល្លារ។ ការនាំចេញរបស់កូរ៉េបានកើនឡើងក្នុងរយៈពេល១៣ ខែជាប់គ្នា ហើយខែវិច្ឆិកាគឺជាខែដំបូងនៃកំណត់ត្រាដែលការនាំចេញបានឡើងរហូតដល់ ៦០ ប៊ីលានដុល្លារ។

ក្នុងចំណោមមុខទំនិញនាំចេញសំខាន់ៗចំនួន ២០ របស់ប្រទេសកូរ៉េ មាន១៧មុខដែលមានភាពល្អប្រសើរឡើងក្នុងនោះរួមមានៈ គ្រឿងអេឡិចត្រូនិក គីមីឥន្ធនៈ(Petrochemicals) គ្រឿងចក្រទូទៅ រថយន្ត ផលិតផលប្រេង ផលិតផលដែក កុំព្យូទ័រ ឧបករណ៍ទំនាក់ទំនងឥតខ្សែ(wireless communication devices) វាយនភណ្ឌ ផលិតផលកសិកម្ម និងនេសាទ សម្ភារៈគីមីល្អ ផលិតផលផ្លាស្ទិច គ្រឿងសម្អាង ឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ និងថ្មបន្ទាប់បន្សំ។ទន្ទឹមនឹងនេះ ក៏មានមុខទំនិញមួយចំនួនដែលការនាំចេញមានការថយចុះដូចជា គ្រឿងបន្លាស់រថយន្ត ថយចុះ២,២% ផលិតផលជីវសុខភាព(Bio-Health)ថយចុះ០,៧% ។

សម្រាប់ការនាំចេញទៅកាន់ប្រទេសចិនបានកើនឡើង ២៧,១% ដែលមានតម្លៃ ១៥,៣ ប៊ីលានដុល្លារ ហើយបានកើនឡើងក្នុងរយៈពេល១៣ខែជាប់ៗគ្នា។ កាកើនឡើងនេះបណ្តាលមកពីតម្រូវការកើនឡើងនូវទំនិញនាំចេញមួយចំនួនដូចជា បន្ទះឈីប(Chip)កើន ៤០,១% ផលិតផលប្រេង១២៥,៥% និងកុំព្យូទ័រកើន ៧៣,៥%។ ស្របពេលជាមួយគ្នានេះដែរ ការនាំចេញទៅកាន់សហភាពអឺរ៉ុបមានចំនួន ៥,៣ ប៊ីលានដុល្លារ កើនឡើង ១៨,៩% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ហើយការនាំចេញទាំងនោះមានដូចជា រថយន្ត គ្រឿងយន្តទូទៅជាដើម។ *ដោយ មុំ ចិន្តា*

**កំណើននៃការនាំចេញរបស់ប្រទេសកូរ៉េក្នុងរយៈពេល ១១ខែ ឆ្នាំ២០២១**




*ប្រភព៖ Ministry of Trade Industry and Energy*

## នៅក្នុងឆ្នាំ២០២២ ឱនភាពថវិការបស់ប្រទេសឥណ្ឌូនេស៊ីនឹងធ្លាក់ចុះទាបជាង ៤,៨៥% នៃផ.ស.ស



*ប្រភព៖ Reuters*

ឱនភាពថវិការបស់ប្រទេសឥណ្ឌូនេស៊ីនៅក្នុងឆ្នាំ ២០២២ អាចនឹងមានកម្រិតទាបជាងការព្យាករណ៍ ៤,៨៥% នៃផ.ស.ស ដោយសារតែការប្រមូលចំណូលរបស់ឥណ្ឌូនេស៊ីមានសក្តានុពលជាងមុន។ យុទ្ធសាស្ត្រចំណូលនេះត្រូវបានដាក់ចេញដោយផ្អែកលើលក្ខខណ្ឌទីផ្សារហិរញ្ញវត្ថុ និងការបង្កើតប្រាក់ចំណូលនៅក្នុងអំលុងពេលដែលសេដ្ឋកិច្ចកំពុងតែប្រឈម។ ខណៈដែលធនាគកណ្តាលនានានៅក្នុងពិភពលោកកំពុងតែរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ។ គួរបញ្ជាក់ថា យុទ្ធសាស្ត្របំណុលរបស់ឥណ្ឌូនេស៊ីនៅក្នុងឆ្នាំ២០២២ មានបីគឺ៖ «កាលានុវត្តភាព ភាពបត់បែន និងប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់»។ ប្រទេសឥណ្ឌូនេស៊ីគ្រោងបោះផ្សាយមូលបត្រ

បំណុលជាប្រាក់រូពីនៅក្នុងក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដែលយុទ្ធសាស្ត្រនេះនឹងជួយឱ្យគោលដៅមូលបត្របំណុលលក់រាយកើនឡើងពី ៩៧ទ្រីលានរូពីក្នុងឆ្នាំ២០២១ ដល់ ១០០ពាន់ពាន់លានរូពីក្នុងឆ្នាំ២០២២ ឬ ស្មើនឹង៦,៩៧ប៊ីលានដុល្លារ។

*ដោយ **វង្ស ច័ន្ទស្មើដារា***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១*

## ធនាគារពិភពលោករក្សាកំណើនសេដ្ឋកិច្ចរបស់ថៃត្រឹម ១% នៅក្នុងឆ្នាំ២០២១ ដោយរំពឹងថាអាចនឹងមានភាពល្អប្រសើរនៅក្នុងឆ្នាំ២០២២



*ប្រភព៖ Reuters*

ធនាគារពិភពលោករំពឹងថា សេដ្ឋកិច្ចរបស់ថៃនឹងមានកំណើន ១% នៅក្នុងឆ្នាំ២០២១ នេះ ហើយអាចនឹងមានកំណើនដល់ទៅ ៣,៩% នៅក្នុងឆ្នាំ២០២២។ ដោយសារតែប្រទេសថៃបានចាប់ផ្តើមបើកទទួលភ្ញៀវទេសចរណ៍បរទេសដែលបានចាក់វ៉ាក់សាំងរួច និងបានបន្ធូរបន្ថយវិធានការរឹតបន្តឹង នាំឱ្យមានការរំពឹងថាសកម្មភាពសេដ្ឋកិច្ចនៅក្នុងវិស័យសេវាកម្មនៅប្រទេសថៃមានសញ្ញាណងើបឡើងវិញ។

គួររំលឹកថា កំណើនសេដ្ឋកិច្ចលំដាប់លេខពីរនៅអាស៊ីអាគ្នេយ៍មួយនេះធ្លាក់ចុះ ៦,១% កាលពីឆ្នាំទៅ។ខណៈដែលសកម្មភាពសេដ្ឋកិច្ចនៅប្រទេសថៃនៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១ ហាក់មានកំណើនយឺត។ គួរបញ្ជាក់ថា ចំនួនភ្ញៀវទេសចរណ៍បរទេសរបស់ប្រទេសថៃនៅក្នុងឆ្នាំនេះមានចំនួនតិចតួចបំផុត។ ប៉ុន្តែការព្យាករណ៍បានរំពឹងថា ចំនួនភ្ញៀវទេសចរណ៍អាចនឹងកើនឡើងជិត ៧លាននាក់នៅក្នុងឆ្នាំ២០២២ និងអាចកើនដល់ ២០លាននាក់ក្នុងឆ្នាំ២០២៣។

ប៉ុន្តែទោះជាយ៉ាងណា លោក Kiatipong Ariyapruchya សេដ្ឋវិទូរជាន់ខ្ពស់របស់ធនាគារពិភពលោកប្រចាំប្រទេសថៃបាននិយាយថា ការព្យុករណ៍នេះហាក់មានភាពស្រពិចស្រពិល និងមិនច្បាស់លាស់ ដោយសារតែសេដ្ឋកិច្ចរបស់ថៃប្រឈមនឹងកូវីដបំប្លែងថ្មីឈ្មោះ Omicron។ ហេតុនេះ ប្រសិនបើរដ្ឋាភិបាលថៃចាត់វិធានការទប់ស្កាត់ និងបិតព្រំដែន នោះសេដ្ឋកិច្ចរបស់ថៃនឹងធ្លាក់ចុះ ០,៣%នៅក្នុងឆ្នាំ ២០២២។

*ដោយ **វង្ស ច័ន្ទស្មើដារា***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១*

## សហរដ្ឋអាមេរិកសម្លឹងឆ្ពោះទៅ រកកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ីដ៏មានឥទ្ធិពលមួយនៅ ឆ្នាំ២០២២ខាងមុខ



*ដោយ freshnews*

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអាមេរិកបានឱ្យដឹងថា រដ្ឋាភិបាលលោកប្រធានាធិបតី Joe Biden មានបំណងចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដែលអាចជាកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ច ដ៏មានឥទ្ធិពលខ្លាំងជាមួយប្រទេសអាស៊ីនៅឆ្នាំ២០២២។ កិច្ចព្រមព្រៀងនេះនឹងផ្តោតសំខាន់លើវិស័យមួយចំនួនរួមទាំងការសម្របសម្រួលសង្វាក់ផ្គត់ផ្គង់ ការគ្រប់គ្រងការនាំចេញ និង

ស្តង់ដារសម្រាប់បញ្ញាសិប្បនិម្មិត (AI) ផងដែរ។ អាមេរិកមិនបានបង្ហាញខ្លួននៅក្នុងតំបន់អាស៊ីអស់រយៈពេល ៤ឆ្នាំហើយ។ តម្រូវការសម្រាប់វត្តមានអាមេរិក និងតម្រូវការសម្រាប់ការចូលរួមឡើងវិញរបស់អាមេរិក ជាអាទិភាពខ្ពស់។ អ្វីដែលជាចក្ខុវិស័យរបស់រដ្ឋាភិបាលអាមេរិកគឺជាក្របខ័ណ្ឌសេដ្ឋកិច្ចប្រភេទថ្មីមួយសម្រាប់សេដ្ឋកិច្ចថ្មីមួយ ហើយក្តីសង្ឃឹមនឹងកើតមាននៅដើមឆ្នាំថ្មី ត្រីមាសទី១ ឆ្នាំក្រោយ ចាប់ផ្តើមដំណើរការជាផ្លូវការ។ ក្របខ័ណ្ឌសេដ្ឋកិច្ចនេះនឹងមានភាពបត់បែនដោយប្រទេសមួយចំនួន ប្រហែលជាមិនចាំបាច់ចូលរួមក្នុងគ្រប់សមាសធាតុទាំងអស់ នៃក្របខ័ណ្ឌនេះឡើយ ហើយគោលបំណងរបស់ក្របខ័ណ្ឌនេះ មិនត្រឹមតែដើម្បីភ្ជាប់ទំនាក់ទំនងជាមួយប្រទេសអភិវឌ្ឍន៍ ដូចជាជប៉ុន អូស្ត្រាលី សិង្ហបុរី និងនូវែលសេឡង់ប៉ុណ្ណោះទេ តែថែមទាំងរួមបញ្ចូលទាំងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាម៉ាឡេស៊ី វៀតណាម និងថៃផងដែរ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២១។*

## ធនាគារពិភពលោក ផ្តល់កម្ចី ៦០០លានដុល្លារ សម្រាប់ហ្វីលីពីន ស្តារសេដ្ឋកិច្ចឡើងវិញ



*ប្រភព ៖ dap-news*

ធនាគារពិភពលោក បានឈានទៅដល់ការចុះកិច្ចព្រមព្រៀង យល់ព្រមផ្តល់កម្ចីនូវទំហំទឹកប្រាក់ ប្រមាណជា ៦០០លានដុល្លារ ទៅឱ្យប្រទេសហ្វីលីពីន ដើម្បីជួយស្តារ សេដ្ឋកិច្ចឡើងវិញ។ កម្ចីនេះយកទៅជួយគាំទ្រដល់រដ្ឋាភិបាលជាមួយ នឹងកំណែទំរង់ដែល កំពុងដំណើរការស្រាប់ ដែលជួយអាចលើកកំពស់វិស័យឯកជនផង កាត់បន្ថយថ្លៃដើមអាជីវកម្មផង និងពង្រីកវិសាលភាពនៃសេវាកម្មលើវិស័យវិនិយោគ ព្រមទាំងបច្ចេកវិទ្យា ចែករំលែកព័ត៌មាន។

យោងតាមការបញ្ជាក់ របស់ប្រធានគ្រប់គ្រងធនាគារពិភពលោកប្រចាំប្រទេសប្រ៊ុយណេ ម៉ាឡេស៊ី ហ្វីលីពីន និងថៃ បានបញ្ជាក់ថាកំណែទំរង់ទាំងនោះ នឹងមានសារៈសំខាន់បំផុត ក្នុងការដោះស្រាយបានភ្លាមៗ ទាំងឧបសគ្គរយៈពេលវែង និងក៏ដូចជាត្រួសត្រាយផ្លូវធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចអាចដំណើរការវិញបានល្អប្រសើរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ dap-news ចេញផ្សាយថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២១។*

## អតិផរណាថៃ នឹងមានដល់ ៣% នៅឆ្នាំ២០២២ ជាអត្រាខ្ពស់បំផុតក្នុងរយៈពេល១ទសវត្សរ៍ចុងក្រោយនេះ




*ដោយ ខេមបុណ្ណមីស(រូបតំណាង: អតិផរណាថៃ)*

អត្រាអតិផរណារបស់ប្រទេសថៃ នឹងមានរហូតដល់ ៣% នៅឆ្នាំ២០២២ ដែលជាកម្រិតខ្ពស់បំផុតមួយមិនធ្លាប់មានពីមុនមក ក្នុងរយៈពេល១ទសវត្សរ៍ចុងក្រោយនេះ។

អគ្គនាយក នៃការិយាល័យគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ថៃ បាននិយាយថា អត្រាអតិផរណាថៃ ទំនងជានឹងកើនដល់ ៣% នៅឆ្នាំ២០២២ ពី

កម្រិត ០,៨% ទៅដល់ ១,២% នៅឆ្នាំ២០២១នេះ។ ការព្យាករនេះ ដោយសន្មតថា មេរោគបំប្លែងថ្មីអូមីក្រុង គឺមិនមានស្ថានភាពធ្ងន់ធ្ងរនោះទេ ព្រមជាមួយនឹងក្តីសង្ឃឹមថា ការបើកប្រទេសឡើងវិញនឹងនាំមកនូវការងើបឡើងនៃសកម្មភាពសេដ្ឋកិច្ច និងទេសចរណ៍ រួមទាំងតម្រូវការក្នុងស្រុក និងការចំណាយកើនឡើងកាន់តែខ្ពស់ផងដែរ។ កត្តាផ្សេងទៀត ដែលរួមចំណែកធ្វើឱ្យអត្រាអតិផរណារីកកាន់តែធំនោះ គឺដោយសារតែការខ្វះខាតកម្លាំងពលកម្ម និងផលប៉ះពាល់នៃកត្តាខាងក្រៅ ដូចជាការនាំចូលវត្ថុធាតុដើមមានតម្លៃកាន់តែខ្ពស់រួមមាន ដែកថែប និងជីកសិកម្មជាដើម និងតម្លៃប្រេងក៏បន្តកើនឡើងខ្ពស់ផងដែរ។

អតិផរណា នឹងជះផលអវិជ្ជមានទៅដល់ប្រាក់បៀវត្សរ៍កម្មករនយោជិត និងប្រាក់ចំណូលកសិករជាដើម ដោយសារតែការចំណាយលើថ្លៃទំនិញមានការឡើងថ្លៃ។ អគ្គនាយក នៃការិយាល័យគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ថៃ បានស្នើទៅដល់រាជរដ្ឋាភិបាល ឱ្យមានការដាក់ចេញឡើងវិញនូវគម្រោងឧបត្ថម្ភធនសម្រាប់ការចំណាយលើថ្លៃទឹក-ភ្លើង និងវិធានការសង្គ្រោះផ្សេងទៀត ដើម្បីជួយកាត់បន្ថយថ្លៃចំណាយសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា កាលពីសប្តាហ៍មុន ការិយាល័យគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ថៃបានព្យាករថា អត្រាអតិផរណា ត្រូវបានវាស់វែងដោយសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ដែលនឹងមានដល់ចន្លោះពី ០,៧% ដល់ ២,៤% ដែលមានជាមធ្យម ១,៥% នៅឆ្នាំ២០២២ ប៉ុន្តែការព្យាករនេះ មិនបានរាប់បញ្ចូលកត្តាមេរោគបំប្លែងថ្មី អូមីក្រុង នោះទេ។ ការព្យាករនេះទៀតសោត ក៏ផ្អែកទៅលើកំណើនសេដ្ឋកិច្ចថៃ ដែលត្រូវបានរំពឹងថា នឹងកើនប្រមាណ ៣,៥% ទៅ៤,៥% នៅឆ្នាំ២០២២ ខណៈតម្លៃប្រេងឆៅនៅទីផ្សារទីក្រុងឌូបៃជាមធ្យមតម្លៃ ៦៣ ទៅ៧៣ដុល្លារក្នុងមួយបារ៉ែល និងអត្រាប្តូរប្រាក់១ដុល្លារអាមេរិក ដូរបាន ៣១,៥ បាត ទៅ ៣៣,៥បាត។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### ធនាគារអភិវឌ្ឍអាស៊ី(ADB) បន្ទាបការព្យាករកំណើនសេដ្ឋកិច្ច នៃប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ឆ្នាំ២០២១ និងឆ្នាំ២០២២




*ប្រភព៖ Asia Development Bank ២០២១*

ជុំវិញការព្រួយបារម្ភលើវីរុសបំប្លែងថ្មី អូមីក្រុង ដែលនាំមកនូវហានិភ័យ និងភាពមិនប្រាកដប្រជា ធនាគារ ADB បានបន្ទាបការព្យាកររបស់ខ្លួន ទៅលើកំណើនសេដ្ឋកិច្ចនៃប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី ដោយបានព្យាករថា សេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីឆ្នាំ២០២១ នឹងមានកំណើន ៧,០% និងឆ្នាំ២០២២ កំណើន ៥,៣% ដែលធ្លាក់ចុះពីការព្យាករខែកញ្ញា ដែលមានអត្រា ៧,១% និង ៥,៤%រៀងគ្នា។

ទន្ទឹមនេះដែរ ធនាគារ ADB ក៏បានគូសសម្គាល់ថា ថ្វីបើស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ បានថយចុះនៅក្នុងប្រទេសកំពុងអភិវឌ្ឍនៅអាស៊ី តែការរីករាលលើពិភពលោកបានកើនឡើង ក៏ដូចជាការងើបឡើងនៃវីរុសបំប្លែងថ្មីឆ្លងរហ័ស ដែលបច្ចុប្បន្នរីករាលដាលដល់ជាង ៦០ប្រទេស។

សេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍនៅអាស៊ីភាគច្រើន ត្រូវបានព្យាករមានកំណើនយឺតជាងការរំពឹងទុក ដែលមួយផ្នែកដោយសារតែកំណើនសេដ្ឋកិច្ចចិនមានភាពទន់ខ្សោយ។

ចំពោះសេដ្ឋកិច្ចអាស៊ាន ត្រូវបានព្យាករនឹងមានកំណើន ៣,០% នៅឆ្នាំ២០២១ ធ្លាក់ចុះ ០,១ពិន្ទុភាគរយធៀបនឹងការព្យាករខែកញ្ញា ដោយសារតែ កំណើនសេដ្ឋកិច្ចយឺតក្នុងត្រីមាសទី៣។ ក៏ប៉ុន្តែ សម្រាប់ឆ្នាំ២០២២ ADB បានបង្កើនការព្យាករកំណើនសេដ្ឋកិច្ចអាស៊ានពី ៥,០% ទៅ ៥,១%៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១*

## សេដ្ឋវិទូរំពឹងថា អតិផរណាក្នុងសហរដ្ឋអាមេរិក នឹងថមថយចុះឆាប់ៗនេះ




*ប្រភព៖ Arkansas Democrat Gazette ២០២១, រូបភាព៖ Elaine Thompson*

យោងតាមការប៉ាន់ស្មានរបស់សេដ្ឋវិទូជាច្រើន សម្រាប់រយៈពេលពីរបីខែខាងមុខនេះ អត្រាអតិផរណានៅក្នុងសហរដ្ឋអាមេរិក នឹងបន្តនៅកម្រិតខ្ពស់បច្ចុប្បន្ន ក៏ប៉ុន្តែនឹងថយចុះមកនៅកម្រិតសមរម្យមួយ រហូតដល់ដំណាច់ឆ្នាំ២០២២។ ទន្ទឹមនេះ គ្រួសារក៏នឹងអាចឃើញពីភាពធូរស្រាលនៃតម្លៃទំនិញមួយចំនួន ក្នុងប៉ុន្មានសប្តាហ៍ខាងមុខ។

ជាក់ស្តែងតម្លៃប្រេងឆៅ និងឧស្ម័នធម្មជាតិលើសកលលោក បានធ្លាក់ចុះ ដែលនេះនឹងជួយទប់ទល់នឹងការកើនឡើងថ្លៃនៃផលិតផលផ្សេងទៀត ក្នុងសេដ្ឋកិច្ច។ គួរបញ្ជាក់ថា តម្លៃទំនិញសម្រាប់អ្នកប្រើប្រាស់ បានកើនឡើង ៦,៨% សម្រាប់រយៈពេល ១២ខែ ដែលនេះ ជាកំណត់ត្រាខ្ពស់មួយក្នុងរយៈពេល ៣៩ឆ្នាំ។ ហើយអតិផរណា( សន្ទស្សន៍តម្លៃសម្រាប់អ្នកប្រើប្រាស់ )នេះ នឹងបន្តនៅកម្រិតខ្ពស់ជាងមុនវិបត្តិ ទោះបីជាមានភាពថមថយចុះ ក្នុងឆ្នាំ២០២២ ខណៈដែល ក្នុង១ទស្សវត្សរ៍ចុងក្រោយនេះ អត្រាអតិផរណាស្ថិតក្រោម ២% និងក្នុងឆ្នាំ២០១៥ មានពេលខ្លះ ឈានទៅក្រោម ០%។

លោក Nela Richardson ប្រធានសេដ្ឋវិទូ នៃ ADP បានលើកឡើងថា ថ្វីបើអត្រាអតិផរណា ក្នុង២០២២ ស្ថិតក្នុងកម្រិតសមរម្យ តែជាក់ស្តែង ថ្លៃនៅតែកើនឡើងគ្រាន់តែមានកំណើនតិចប៉ុណ្ណោះ។ រីឯ លោក Russell Price បានរំពឹងថា អតិផរណានៅខែធ្នូ និងខែមករាខាងមុខនេះ នឹងមានអត្រា ៧,១% ហើយនឹងថយចុះមក ៤% នៅក្នុងរដូវក្តៅនេះ និងក្រោម៣% រហូតដល់ដំណាច់ឆ្នាំ ២០២២៕ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Arkansas Democrat Gazette ចេញផ្សាយ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១*

## តម្លៃប្រេងរំកិលឡើងបន្តិចទៀតហើយ ក្រោយដំណឹងថា អូមីក្រុង មិនធ្វើឱ្យមនុស្សធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ



*ដោយ ខេមបុណ្ណមីស*

តម្លៃប្រេងនៅដើមសប្តាហ៍នេះបានឡើងបន្តិច ក្រោយពីមានការបង្ហាញថា មេរោគបំប្លែងថ្មី អូមីក្រុង មិនអាចធ្វើឱ្យមនុស្សធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។ តម្លៃប្រេងឆៅនៅទីផ្សារអង់គ្លេសបានកើនឡើងជិត១ដុល្លារបន្ថែមទៀត

ហើយនៅអាមេរិកវិញ បានកើនឡើងជាង១ដុល្លារបន្ថែមដែរ។ អ្នកវិនិយោគជឿជាក់ថា មេរោគបំប្លែងថ្មី មិនជះឥទ្ធិពលធ្ងន់ធ្ងរដល់ទីផ្សារសកលនោះទេ។ អ្នកវិនិយោគ កំពុងតាមដានយ៉ាងយកចិត្តទុកដាក់ចំពោះអង្គការ OPEC+ នាកិច្ចប្រជុំមួយនៅខែមករាខាងមុខនេះ ខណៈកាលពីដើមខែមុន អង្គការOPEC+ បានព្រមព្រៀងប្រកាន់ខ្ជាប់នូវគោលនយោបាយបង្កើនទិន្នផលប្រេងប្រចាំខែរបស់ខ្លួន។ កាលពីសប្តាហ៍មុន សហរដ្ឋអាមេរិកបានប្រកាសថា បញ្ចេញលក់ប្រេងឆៅចំនួន ១៨លានបារ៉ែលពីស្តុកប្រេងបម្រុងរបស់ខ្លួន នៅខែធ្នូ ហើយនឹងបញ្ចេញប្រេងពីស្តុកបម្រុងរបស់ខ្លួនសរុបដល់ជាង៥០លានបារ៉ែល ដើម្បីបន្ទាបតម្លៃប្រេងដែលកំពុងមានខ្ពស់នាពេលបច្ចុប្បន្ននេះ៕

*ដោយ ម៉ែន ខែមរៈ*

ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។

**ចិននឹងចាប់ផ្តើមអនុវត្តច្បាប់នាំចូលចំណីអាហារថ្មី នៅដើមឆ្នាំក្រោយ(អាមេរិក និងអឺរ៉ុបបារម្ភថា រំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់)**




*ដោយ ខេមបូណ្ឌមីស*

ច្បាប់ថ្មីរបស់ចិនទាក់ទងនឹងការនាំចូលចំណីអាហារ នឹងត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែមករាឆ្នាំ២០២២ ខាងមុខនេះ ទៅតាមផែនការដែលបានគ្រោងទុក។ ច្បាប់ថ្មីនេះ តម្រូវឱ្យក្រុមហ៊ុនផលិត កែច្នៃ និងស្តុកចំណីអាហារនៅក្រៅប្រទេសទាំងអស់ ត្រូវតែចុះបញ្ជីនៅជាមួយរដ្ឋបាលគយចិន។ វិធានការនេះនឹងជួយបង្កើត ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ និងធានាបានថា ចំណីអាហារនាំចូលទាំងនោះ គឺត្រឹមត្រូវតាមស្តង់ដារសុវត្ថិភាព និងបទប្បញ្ញត្តិជាតិរបស់ចិន។ ដូច្នេះ ការនាំចូលចំណីអាហារនៅក្នុងប្រទេសចិននៅឆ្នាំក្រោយ នឹងត្រូវជួបនូវការរឹតត្បិត ការត្រួតពិនិត្យ។ វិធានការរឹតបន្តឹងលើប្រភេទផលិតផលចាប់តាំងពី អាហារបំប៉ន ប្រេងឆា និងអាហារសម្រាប់កុមារជាដើម។ កន្លងមកដៃគូពាណិជ្ជកម្មធំៗរបស់ចិនរួមមានអាមេរិក និងអឺរ៉ុប បានទទូចឱ្យក្រុងប៉េកាំងពន្យារពេលក្នុងការអនុវត្តច្បាប់នេះ ព្រោះថា គោលនយោបាយដែលមាននៅក្នុងច្បាប់ថ្មីនេះ នឹងធ្វើឱ្យរំខានដល់ខ្សែចង្វាក់ផ្គត់ផ្គង់នៅពេលខាងមុខ។ អ្នកការទូតមកពីប្រទេសសេដ្ឋកិច្ចធំៗទាំង៧ ដែលរួមទាំងអូស្ត្រាលី ជប៉ុន កាណាដា និងប្រទេសស្វីសផងដែរនោះ បានទទូចឱ្យចិនពន្យារពេលអនុវត្តគោលនយោបាយនេះ យ៉ាងតិច១៨ខែសិន ដោយបញ្ជាក់ថា វានៅខ្វះភាពច្បាស់លាស់អំពីរបៀបដែលវានឹងត្រូវបានអនុវត្ត ព្រោះការបរាជ័យក្នុងការអនុវត្តតាមច្បាប់ថ្មីនេះ នឹងបណ្តាលឱ្យមានការពន្យារពេលដឹកជញ្ជូន និងអាចបង្កជាហានិភ័យទៅដល់ខ្សែសង្វាក់ផ្គត់ផ្គង់ចំណីអាហារសកលផងដែរ នៅគ្រាដែលពិភពលោកបច្ចុប្បន្ននេះ កំពុងជួបប្រទះនឹងការកកស្ទះការដឹកជញ្ជូនធ្ងន់ធ្ងររួចទៅហើយនោះ ដោយសារតែជំងឺរាតត្បាតកូវីដ១៩៕ *ដោយ ម៉ែន ខែមរៈ*

ប្រភព ៖ ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

## អាមេរិក និងតៃវ៉ាន់ ចាប់ផ្តើមរកាំរកូសជាថ្មី លើរឿងពាណិជ្ជកម្មសាច់ជ្រូក




*ដោយ ខេមបូណ្ណមីស*

កាលពីឆ្នាំ២០០០មក កោះតៃវ៉ាន់បានដាក់បម្រាមមិនឱ្យនាំសាច់គោអាមេរិកចូលក្នុងដែនកោះរបស់ខ្លួនទេ ក្រោយពីមានផ្ទុះជំងឺលើសត្វគោ និងជ្រូកនៅសហរដ្ឋអាមេរិក។ នាឆ្នាំ២០២០ ថ្នាក់ដឹកនាំកោះតៃវ៉ាន់បានលើកបម្រាមនេះចេញដោយសារតែឥទ្ធិពលនយោបាយ និងទំនាក់ទំនងជាមួយអាមេរិក ហើយក៏បានអនុញ្ញាតឱ្យនាំចូលសាច់គោ និងសាច់ជ្រូកពីអាមេរិកឡើងវិញ ទោះដឹងថាមានសារជាតុគីមីប៉ះពាល់ដល់សុខភាពក៏ដោយ។ ប្រការនេះធ្វើឱ្យសាច់ជ្រូកអាមេរិកដែលចិញ្ចឹមដោយប្រើថ្នាំគីមី រ៉េកតូប៉ាមីន (ractopamine)បំប៉នអាចជ្រៀតចូលក្នុងទីផ្សារតៃវ៉ាន់បានឡើងវិញដែរ។ រ៉េកតូប៉ាមីន (ractopamine) ជាសារជាតុគីមីបំប៉នសត្វ ដែលធ្វើឱ្យសត្វ ធាត់ទ្រលក់ទ្រលន់សាច់ពេញ មានប្រើប្រាស់ច្រើនក្នុងកសិកម្មចិញ្ចឹមសត្វនៅតំបន់អាមេរិកខាងជើង តែថ្នាំនេះត្រូវជាប់បម្រាមមិនឱ្យប្រើប្រាស់ទេ នៅតំបន់អឺរ៉ុប ប្រទេសរុស្ស៊ី និងនៅប្រទេសចិន ហើយតៃវ៉ាន់ក៏ធ្លាប់ហាមឃាត់ដែរ ពីមុនមក។ តៃវ៉ាន់ ក៏ពីមានច្បាប់សុវត្ថិភាពនាំចូលសាច់តឹងតែងណាស់ ជាច្បាប់ដែលគិតគូរខ្លាំងដល់សុខភាពអ្នកប្រើប្រាស់។ ពេលនេះពលរដ្ឋតៃវ៉ាន់ជាច្រើនមិនសប្បាយចិត្ត និងបានចេញតាមផ្លូវធ្វើបាតុកម្មប្រឆាំង និងបោះឆ្នោតប្រជាមតិ ស្នើឱ្យមានការហាមឃាត់ការនាំចូលសាច់ជ្រូកពីអាមេរិកឡើងវិញ។ លទ្ធផលបានពីការបោះឆ្នោតប្រជាមតិ នឹងជះឥទ្ធិពលមិនល្អ ដល់សំណើរបស់តៃវ៉ាន់ ដើម្បីចូលរួមក្នុងកិច្ចព្រមព្រៀង CP TPP បើទោះជា អាមេរិកលែងជាសមាជិកហើយក្តី ប៉ុន្តែនៅមានសម្ព័ន្ធមិត្តរបស់អាមេរិកជាច្រើនទៀតនៅជាសមាជិកនៃកិច្ចព្រមព្រៀងនេះ។ បន្ថែមពីលើនេះ វាក៏អាចប៉ះពាល់ដល់ទំនាក់ទំនងមួយផ្នែករវាងទីក្រុងតៃប៉ិ និងវ៉ាស៊ីនតោនផងដែរ៕

*ដោយ ម៉ែន ខែមវរៈ*

*ប្រភព ៖ ខេមបូណ្ណមីស ចេញផ្សាយថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២០ ខែធ្នូ ឆ្នាំ២០២១

- អតិរេកគណនីចរន្តរបស់តំបន់អឺរ៉ូបានរួមតូចដល់ 26.9 ពាន់លានអឺរ៉ូក្នុងខែកញ្ញា ឆ្នាំ 2021 ពី 37.8 ពាន់លានអឺរ៉ូកាលពីឆ្នាំមុន
- កំណើនបំណុលរដ្ឋាភិបាលលប្រទេសទួរគី ក្នុងខែ កញ្ញាឆ្នាំ 2021នៃ

ថ្ងៃអង្គារ ទី២១ ខែធ្នូ ឆ្នាំ២០២១

- កំណើនខ្ពស់បំផុតការខ្ចីប្រាក់សុទ្ធ ពីវិស័យសាធារណៈនៅចក្រភពអង់គ្លេស ក្នុងខែតុលា ឆ្នាំ 2021 ដែលជាការខ្ចីបខ្ពស់បំផុតទីពីរចាប់តាំងពី ឆ្នាំ 1993
- តម្រូវការសរុប នៅក្នុងប្រទេសម៉ិកស៊ិកបានថយចុះ នៅក្នុងត្រីមាសទីពីរនៃឆ្នាំ 2021

ថ្ងៃពុធ ទី២២ ខែធ្នូ ឆ្នាំ២០២១

- ការថយចុះអត្រានិកម្មភាព នៅប្រទេសអាហ្សង់ទីន នៅក្នុងត្រីមាសទីពីរនៃឆ្នាំ 2021
- សេដ្ឋកិច្ចអាមេរិកបានពង្រីកប្រចាំឆ្នាំ 2.1% នៅត្រីមាសក្នុងត្រីមាសទី 3 ឆ្នាំ 2021 ដែល

ខ្ពស់ជាងបន្តិច 2% នៅក្នុងការប៉ាន់ស្មានជាមុន ប៉ុន្តែទាបជាងការព្យាករណ៍ 2.2%

ថ្ងៃព្រហស្បតិ៍ ទី២៣ ខែធ្នូ ឆ្នាំ២០២១

- កំណើនតម្លៃនាំចូលនៅប្រទេសអាឡឺម៉ង់បានកើនឡើង ក្នុងខែតុលា ឆ្នាំ 2021
- អត្រានិកម្មភាព របស់ម៉ិកស៊ិកបានថយចុះមកត្រឹម 3.9 ភាគរយក្នុងខែតុលា ឆ្នាំ 2021

ថ្ងៃសុក្រ ទី២៤ ខែធ្នូ ឆ្នាំ២០២១

- កំណើនភ្ញៀវទេសចរណ៍បរទេសដែលមកទស្សនាប្រទេសទួរគី ក្នុងខែតុលា ឆ្នាំ 2021
- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ក្នុងប្រទេសជប៉ុនបានធ្លាក់ចុះ 0.30%ក្នុងខែតុលា ឆ្នាំ 2021 ធៀបនឹងខែមុន។